ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ០១៥
ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៧
**សាលក្រមលេខ** ០២(ញ)
ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧

តាងនាមប្រជារាស្ត្រខ្មែរ
**សាលាដំបូងខេត្តកណ្ដាល**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧
ដោយមានសមាសភាព:

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ [redacted] **សុតី** ភេទស្រី អាយុ ៤៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរតម្បាញ មានទីលំនៅបច្ចុប្បន្ននៅ[redacted]។

មានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

-ចុងចម្លើយឈ្មោះ [redacted] **ផល្លា** ភេទប្រុស អាយុ ៤៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប មានទីលំនៅបច្ចុប្បន្នភូមិ[redacted]។

មានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ ។

## អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:**

-សុំលែងលះពីចុងចម្លើយឈ្មោះ មុំ ផល្លា។

-សុំឲ្យចុងចម្លើយគ្រប់គ្រងកូនចំនួន ០៣ នាក់ ទី១ ឈ្មោះ [redacted] វិបុល អាយុ២៥ឆ្នាំ , ទី២ ឈ្មោះ [redacted] ស្រីនាង អាយុ ២៣ឆ្នាំ និងទី៣ ឈ្មោះ [redacted] សីហា អាយុ ៩ឆ្នាំ ។

-សុំបែកចែកទ្រព្យសម្បត្តិរួមមាន ម៉ូតូ១គ្រឿង ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្ដី:**

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ១៩៩១ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ ។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា គូភាគីមានកូនចំនួន ០៣នាក់ ។ ចំពោះទ្រព្យសម្បត្តិរួមមាន ម៉ូតូ១គ្រឿង និងបំណុលគ្មាន ។ នៅក្នុងការរស់នៅជាមួយគ្នាមានភាពមិនចុះសម្រុង តែងតែឈ្លោះប្រកែកគ្នាជាញឹកញាប់ ធ្វើឲ្យអស់មនោសញ្ចេតនា ជាប្តីប្រពន្ធតទៅទៀត ។

**៣-ការអះអាងរបស់ភាគី:**

-ដើមចោទឈ្មោះ [redacted] **សុតី** បានអះអាងថា: ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយ ចុងចម្លើយនៅឆ្នាំ ១៩៩១ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ត្រឹមត្រូវតាមច្បាប់ទេ ។ ការរស់នៅជាមួយគ្នា ពួកខ្លួនមានកូន៣នាក់ កូនទី១ ឈ្មោះ [redacted] វិបុល ភេទប្រុស អាយុ២៥ឆ្នាំ , កូនទី២ឈ្មោះ:

[redacted] ស្រីនាង ភេទស្រី អាយុ២៣ឆ្នាំ និងកូនទី៣ ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ០៨ឆ្នាំ ។ ការរួមរស់មានភាពមិនចុះសម្រុងនឹងគ្នា ដោយមានការទាស់ទែងគ្នា និងការជេរប្រមាថគ្នាជាញឹកញាប់ រហូតដល់អស់មនោសញ្ចេតនានឹងគ្នាជាប្ដីប្រពន្ធតទៅទៀត ។ ទ្រព្យសម្បត្តិរួមមានម៉ូតូសេ១២៥ ចំនួន ០១គ្រឿង ដែលកូនប្រុសឈ្មោះ [redacted] វិបុល បានទិញឲ្យ។ ចំពោះដីនិងផ្ទះដែលរស់នៅសព្វថ្ងៃ ម្ដាយរបស់ខ្លួនគាត់លក់ដីនៅជម្ពូវ័ន្ត ហើយឲ្យលុយខ្លួនចំនួន ៣,០០០(បីពាន់)ដុល្លាអាមេរិក មកទិញដីនោះ ក្នុងតម្លៃ ២,៧០០ ដុល្លាអាមេរិក នៅសល់ ៣០០ដុល្លាអាមេរិក ខ្លួនទិញកីតម្បាញ ។ ចំពោះបំណុលរួមគ្មាន។ រីឯការលើកឡើងរបស់ចុងចម្លើយ ដែលថាម្ដាយរបស់គាត់បានឲ្យលុយចំនួន ២,០០០(ពីរពាន់)ដុល្លាអាមេរិក គឺឲ្យនៅក្រោយទិញដីផ្ទះ និងដីបានរយៈពេល១០ឆ្នាំហើយ គឺឲ្យយកមកទិញគោចិញ្ចឹម ក្រោយមកក៏បានលក់គោនោះ មកដោះស្រាយជីវភាពអស់ហើយ ។ ឯប្រាក់ចំនួន ៨០០(ប្រាំបីរយ)ដុល្លាអាមេរិក នោះគឺពុំមានទេ ។ សាក្សីដឹងឮរឿងទិញលក់ដី មានអ្នកនាំទិញដី និងដឹងពីលុយទិញដី ។

-លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ សុំតុលាការចេញសាលក្រមដូចពាក្យបណ្ដឹង ដែលមានកម្មវត្ថុ:

-ទី១ សុំលែងលះ ។

-ទី២ សុំគ្រប់គ្រងកូន ។

-ទី៣ ចែកម៉ូតូជា២ចំណែក ។

-និងទី៤ សុំគ្រប់គ្រងដី និងផ្ទះ ដែលរស់នៅសព្វថ្ងៃ ព្រោះជាប្រាក់ម្ដាយដើមចោទចែកឲ្យដើមចោទ ដោយមានសាក្សីដឹងឮ ។

-លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនបានឯកភាពក្នុងការលែងលះ ។ ចំពោះកូនឈ្មោះ [redacted] សីហា គឺអាស្រ័យលើការសំរេចចិត្តរបស់កូនចុះ។ ទ្រព្យសម្បត្តិរួមមានម៉ូតូសេ ១២៥ ចំនួន ០១ គ្រឿង ជាអំណោយរបស់កូនឈ្មោះ [redacted] វិបុល គាត់បានទិញឲ្យកូនក្ដីខ្លួនជាឪពុក ។ ចំពោះដីលំនៅដ្ឋានទំហំ ១៣ម៉ែត្រ និងបណ្ដោយ ៦០ ម៉ែត្រ មានផ្ទះឈើប្រក់ស័ង្កសីទំហំ ៥ម៉ែត្រ និងបណ្ដោយ ៦ម៉ែត្រ ស្ថិតនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល គឺជាទ្រព្យសម្បត្តិរួម រវាងកូនក្ដីខ្លួន និងដើមចោទ ដូចមាននៅក្នុងឯកសារ ។ ចំពោះលុយដែលដើមចោទបានលើកឡើងថា ម្ដាយបានប្រគល់ឲ្យចំនួន ៣,០០០(បីពាន់) ដុល្លាអាមេរិកនោះ គឺកូនក្ដីខ្លួនពុំបានដឹងពីចំនួន ហើយមិនដឹងថាដើមចោទយកទៅធ្វើអ្វីដែរ នៅក្នុងនោះម្ដាយរបស់កូនក្ដីខ្លួនក៏បានប្រគល់ប្រាក់ចំនួន ២,០០០(ពីរពាន់)ដុល្លាអាមេរិក គឺឲ្យនៅមុនពេលទិញដីនិងផ្ទះ និងមានប្រាក់ចំនួន ៨០០(ប្រាំបីរយ)ដុល្លាអាមេរិក ដែលបច្ចុប្បន្នដើមចោទជាអ្នកគ្រប់គ្រង ។ ការរស់នៅជាអនីតិសង្វាស តើមានទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិ ដោយឡែកឬទេ ? បើផ្អែកលើប័ណ្ណកម្មសិទ្ធិគឺឈ្មោះទាំង២នាក់ ។ សាក្សីសុទ្ធតែជាបងប្អូនដើមចោទ ដែលអត់ដឹងច្បាស់ទេរឿងលុយ ។ រីឯម៉ូតូសេ ១២៥ គឺកូនទិញឲ្យឪពុកផ្ទាល់ ។ សំណូមពរ សូមបែងចែកដី និងផ្ទះ, រីឯម៉ូតូសូមប្រគល់ឲ្យទៅចុងចម្លើយ ។

**៤-ចំណុចវិវាទ៖** ការបែងចែកទ្រព្យសម្បត្តិ ហើយតើអ្វីខ្លះជាទ្រព្យសម្បត្តិរួម?



Scanned with CamScanner

## សំអាងហេតុ

១-តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយបានមករស់នៅជាមួយគ្នាជាប្តីប្រពន្ធ កាលពីឆ្នាំ ១៩៩៦ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ ។ ដូច្នេះការរួមរស់នៅជាមួយគ្នាជាការរស់នៅបែបអនីតិសង្វាស ពុំមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទេ ។ គូភាគីមានសិទ្ធិនៅក្នុងការរៀបអាពាហ៍ពិពាហ៍គូស្រករថ្មី និងចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់បាន ។ ចំពោះការទាមទារចំណុចនេះ តុលាការគប្បីលើកចោល ដោយសារជាបណ្តឹងខុសច្បាប់ តាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ការរួមរស់ជាមួយគ្នាដើមចោទ និងចុងចម្លើយ មានកូន០៣នាក់

- ឈ្មោះ [redacted] វិបុល ភេទប្រុស អាយុ ២៥ឆ្នាំ ។
- ឈ្មោះ [redacted] ស្រីនាង ភេទស្រី អាយុ ២៣ឆ្នាំ។
- ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ០៨ឆ្នាំ ។

ចំពោះឈ្មោះ [redacted] វិបុល ភេទប្រុស អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] ស្រីនាង ភេទស្រី អាយុ២៣ឆ្នាំ គឺបានដល់នីតិភាពហើយ ដូច្នេះតុលាការមិនពិចារណាសម្រេចអំពីអំណាចមេលើកូនទាំងពីរនាក់នេះ ទេ ។

ដើមចោទបានសុំគ្រប់គ្រងកូនឈ្មោះ [redacted] សីហា ភេទប្រុស អាយុ០៨ឆ្នាំ ដោយមិនទាមទារអាហារកិច្ចចិញ្ចឹមកូនទេ រីឯចុងចម្លើយបានទុកសិទ្ធិឲ្យកូនសម្រេចចិត្ត ។ តាមការសាកសួររបស់តុលាការ កូនឈ្មោះ [redacted] សីហា បានបញ្ជាក់ថា ចង់រស់នៅជាមួយម្តាយ ។ ដូច្នេះតុលាការផ្តល់សិទ្ធិអំណាច មេបាលើកូននេះ ផ្អែកតាមការសម្រេចចិត្តរបស់កូន និងតាមការព្រមព្រៀងរបស់ឪពុកម្តាយ យោង តាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។ ឪពុកដែលមិនមានសិទ្ធិអំណាច មេបាលើកូន ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៣-ដើមចោទបានអះអាងថា ប្រាក់ទិញដីបានមកពីម្តាយរបស់ខ្លួនបានឲ្យចំនួន ៣,០០០(បីពាន់)ដុល្លាអាមេរិក បានយកប្រាក់នេះទិញដីអស់ ២,៧០០(ពីពាន់ប្រាំពីររយ)ដុល្លាអាមេរិក និងសល់ប្រាក់ ៣០០ដុល្លាអាមេរិក យកទៅទិញកីតម្បាញ ។ ដីលំនៅដ្ឋានទំហំ ១៣ម៉ែត្រ និងបណ្តោយ ៦០ ម៉ែត្រ មានផ្ទះលើប្រក់ស័ង្កសីទំហំ ៥ម៉ែត្រ និងបណ្តោយ ៦ម៉ែត្រ ស្ថិតនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បានទិញនៅអំឡុងពេលរស់នៅជាមួយគ្នា ប៉ុន្តែផ្អែកតាមការសាកសួរសាក្សីឈ្មោះ [redacted] សុផល , ឈ្មោះ [redacted] ស៊ីចាន់ , ឈ្មោះ [redacted] ប៊ុនធឿន និងឈ្មោះ [redacted] សារឿន បានបញ្ជាក់ថា: ក្នុងអំឡុងឆ្នាំ ១៩៩៩ ដើមចោទនិងចុងចម្លើយបានមកសុំស្នាក់នៅផ្ទះរបស់ ឈ្មោះ [redacted] សុផល ហើយអ្នកទាំងពីរចង់រកទិញដីស្នាក់នៅ ហើយអ្នកទាំងពីរបានប្រាប់ថា ម្តាយខាង ស្រីចែកលុយឲ្យ ៣,០០០ដុល្លាអាមេរិក ឈ្មោះ [redacted] ស៊ីចាន់ ជាអ្នកនាំទៅទិញដីក្នុងតម្លៃ ២,៧០០ដុល្លាអាមេរិក នៅសល់លុយ ៣០០ដុល្លាអាមេរិក ទិញកីតម្បាញ ។ ហើយបើផ្អែកតាមការពិនិត្យលើលិខិត ផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ រវាងឈ្មោះ [redacted] ចរិយា និងឈ្មោះ [redacted] បូរី ជាមួយឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] សុភី ឃើញថា ដីនេះមានតម្លៃ ២,៧០០ដុល្លា អាមេរិក។ ដូច្នេះការអះអាងរបស់ដើមចោទ អាចឲ្យតុលាការជឿជាក់បានថា ដីនិងផ្ទះដែលគូភាគីកំពុងស្នាក់នៅសព្វថ្ងៃ គឺជាទ្រព្យដែលបានមកពី



Scanned with CamScanner

ប្រទានកម្មរបស់ម្ដាយដើមចោទឲ្យកូន ដូច្នេះយោងតាមបញ្ញត្តិមាត្រា ៩៧២ ចំណុច(ខ) នៃក្រមរដ្ឋប្បវេណី គឺជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ។ រីឯការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយថាទ្រព្យសម្បត្តិនេះគឺជាទ្រព្យសម្បត្តិ រួមដោយផ្អែកលើប័ណ្ណកម្មសិទ្ធិមានឈ្មោះទាំង២នាក់ តុលាការមិនពិចារណាទេ ពីព្រោះដីនេះមិនទាន់មានប័ណ្ណកម្មសិទ្ធិនៅឡើយទេ គឺមានតែលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីប៉ុណ្ណោះ ។

៤-ចំពោះម៉ូតូសេ១២៥ ចំនួន១គ្រឿង ជាអំណោយរបស់កូនឈ្មោះ [redacted] វិបុល មកឲ្យឪពុកឈ្មោះ [redacted] ផល្លា ដើម្បីជិះ ដោយមានប័ណ្ណសំគាល់យានយន្ត ចុះថ្ងៃទី ២១-១២-២០១៥ ដែលមានផ្លាកលេខ ភ្នំពេញ 1FM-2319 ដូច្នេះយោងតាមបញ្ញត្តិមាត្រា ៩៧២ ចំណុច(ខ) នៃក្រមរដ្ឋប្បវេណី គឺជាទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយដែលបានមកពីប្រទានកម្មរបស់កូន។

៥-ចំពោះការអះអាងរបស់ចុងចម្លើយថា ទ្រព្យសម្បត្តិរួមមាន ប្រាក់ចំនួន ៨០០ដុល្លាអាមេរិកនោះ គឺគ្មានភស្តុតាងអ្វីមកបញ្ជាក់អាចឲ្យតុលាការជឿជាក់បានទេ ដូច្នេះតុលាការមិនពិចារណាតាមការអះអាងរបស់ភាគីចុងចម្លើយទេ ។

៦-គូភាគីបានអះអាងថាមិនមានបំណុលរួមទេ ដូច្នេះតុលាការមិនពិចារណាអំពីបញ្ហាបំណុលទេ ។

៧-ចំពោះប្រាក់ប្រដាប់ក្ដីតុលាការគប្បីឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ ពាក់កណ្ដាល ដោយយោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៨-សេចក្ដីសន្និដ្ឋាន:**

-បណ្ដឹងសុំលែងលះ ត្រូវលើកចោល ដោយសារជាបណ្ដឹងខុសច្បាប់ ។

-កូនចំនួន ៣នាក់ តុលាការសម្រេចឲ្យដើមចោទមានសិទ្ធិអំណាចមេបាលើកូនម្នាក់ ឈ្មោះ [redacted] សីហា រីឯកូន២នាក់ទៀត ដែលជាអនីតិជនតុលាការមិនសម្រេចទេ ។

-ចុងចម្លើយត្រូវផ្ដល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

-ដី និងផ្ទះដែលកំពុងរស់នៅ ជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ដែលបានមកពីម្ដាយដើមចោទឲ្យប្រាក់មកទិញ ។

-ម៉ូតូ១គ្រឿង ម៉ាកហុងដា Dream ១២៥ ពាក់ផ្លាកលេខ ភ្នំពេញ 1FM-2319 ជារបស់កូនទិញឲ្យចុងចម្លើយ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ។

-គូភាគីត្រូវទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី ម្នាក់ពាក់កណ្ដាល ។

## សេចក្ដីសម្រេចបញ្ចប់

១-លើកចោលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ [redacted] **សុភី** ត្រង់ចំណុច ដែលសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] **ផល្លា** ។ គូភាគីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍តាមស្រុកកំណើត និងចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់ ។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅដើមចោទឈ្មោះ [redacted] **សុភី** ជាម្ដាយលើកូនម្នាក់ឈ្មោះ [redacted] **សីហា** ភេទប្រុស កើតថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ។



Scanned with CamScanner

ទុកសិទ្ធិឲ្យចុងចម្លើយទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងឲ្យផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣-ប្រគល់ដីលំនៅដ្ឋានទំហំ ១៣ម៉ែត្រ និងបណ្តោយ ៦០ ម៉ែត្រ មានផ្ទះឈើប្រក់ស័ង្កសីទំហំ ៥ ម៉ែត្រ និងបណ្តោយ ៦ម៉ែត្រ ស្ថិតនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឲ្យទៅដើមចោទឈ្មោះ [redacted] **សុភី** គ្រប់គ្រង ។

៤-ប្រគល់ម៉ូតូ១គ្រឿង ម៉ាកហុងដា Dream ១២៥ ពាក់ផ្លាកលេខ ភ្នំពេញ 1FM-2319 ឲ្យទៅចុងចម្លើយឈ្មោះ [redacted] **ផល្លា** គ្រប់គ្រង ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគីម្នាក់ពាក់កណ្តាល ។

**ចៅក្រម**

ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ធ្វើនៅខេត្តកណ្តាល ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner